ក

# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៤-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៤៦ ស្តីពីការបំពាក់ឋានន្តរស័ក្តិកងយោធពលខេមរភូមិន្ទ និងតែងតាំងជាទីប្រឹក្សាក្រសួងការពារជាតិ ចំនួន ០២ រូប ៤៦៤

១៤-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៤៧ ស្តីពីការតែងតាំងប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ចំនួន ០៣ រូប ៤៦៥

១៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៤៨ ស្តីពីការតែងតាំងទីប្រឹក្សា និង ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចំនួន ០៣ រូប ៤៦៦

១៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៤៩ ស្តីពីការតែងតាំងឯកឧត្តម ទ្រឹត ឌុទ្ធី ជាអគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានឋានៈស្មើ អគ្គនាយក ៤៦៧

១៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៥០ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនចំពោះអស់លោក ចំនួន ០៧ រូប ៤៦៨

១៦-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៥១ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះនាយទាហានជាន់ខ្ពស់ ចំនួន ០២ រូប ៤៦៩


## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២៧-០១-២០០៩ -អនុក្រឹត្យលេខ ២៣ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៤៧០

២៧-០១-២០០៩ -អនុក្រឹត្យលេខ ២៤ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអនុគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៤៧៥

២៧-០១-២០០៩ -អនុក្រឹត្យលេខ ២៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៤៨២

២២-០១-២០០៩ -អនុក្រឹត្យលេខ ៧៣ អនក្រ.តត ស្តីពីការតែងតាំងនាយទាហានជាន់ខ្ពស់ ៤៨៤

២២-០១-២០០៩ -អនុក្រឹត្យលេខ ៧៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៤៨៥

២២-០១-២០០៩ -អនុក្រឹត្យលេខ ៧៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៤៨៦

២២-០១-២០០៩ -អនុក្រឹត្យលេខ ៧៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៤៨៧

២២-០១-២០០៩ -អនុក្រឹត្យលេខ ៧៧ អនក្រ.តត ស្តីពីការបញ្ចប់តំណែងនាយទាហានជាន់ខ្ពស់ ៤៨៨

២៣-០១-២០០៩ -អនុក្រឹត្យលេខ ៧៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៨៩

២៦-០១-២០០៩ -អនុក្រឹត្យលេខ ៧៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៩១

២៦-០១-២០០៩ -អនុក្រឹត្យលេខ ៨០ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៩៦

២៦-០១-២០០៩ -អនុក្រឹត្យលេខ ៨១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៤៩៨

២៦-០១-២០០៩ -អនុក្រឹត្យលេខ ៨២ អនក្រ.តត ស្តីពីការតែងតាំង និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៩៩

២៦-០១-២០០៩ -អនុក្រឹត្យលេខ ៨៣ អនក្រ.តត ស្តីពីការតែងតាំង ជំនួយការរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ៥០០

២៦-០១-២០០៩ -អនុក្រឹត្យលេខ ៨៤ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំង មន្ត្រីរាជការ ៥០១

២៦-០១-២០០៩ -អនុក្រឹត្យលេខ ៨៥ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥០២

២៦-០១-២០០៩ -អនុក្រឹត្យលេខ ៨៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៥០៣

២៦-០១-២០០៩ -អនុក្រឹត្យលេខ ៨៧ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥០៥

២៧-០១-២០០៩ -អនុក្រឹត្យលេខ ៨៨ អនក្រ.តត ស្តីពីការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការ នៃក្របខណ្ឌមន្ត្រីក្រមការ ៥០៧

២៧-០១-២០០៩ -អនុក្រឹត្យលេខ ៨៩ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៥១០

២៧-០១-២០០៩ -អនុក្រឹត្យលេខ ៩០ អនក្រ.តត ស្តីពីការតែងតាំងមុខងារ នាយទាហាន ៥១២

២៧-០១-២០០៩ -អនុក្រឹត្យលេខ ៩១ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ៥១៣

២៧-០១-២០០៩ -អនុក្រឹត្យលេខ ៩២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១៥

២៧-០១-២០០៩ -អនុក្រឹត្យលេខ ៩៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥១៦

២៧-០១-២០០៩ -អនុក្រឹត្យលេខ ៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១៧

២៧-០១-២០០៩ -អនុក្រឹត្យលេខ ៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១៨

## III-ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩០៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លែន យ៉ាញ ស្លុក អ៊ិនធើណេសិនណាល ខបភើរេសិន** ៥១៩

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩០៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេម_ខូរៀ ហាយ_ណេត** ៥២១

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩០៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស.អេហ្វ.ដាប់ប៊ែលយូ** ៥២៣

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩០៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយ.ស៊ី.ស៊ី.ស៊ី** ៥២៥

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩១០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រាជបុត្រ ឧត្តរាទេពី ត្រេឌីង** ៥២៧

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩១១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន ប្រូភើធី អ៊ិនធើណេសិណានល ហូលឌីង** ៥២៩

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩១២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីហ្វូ វ៉ាប់ប៊ើ លីមីធីត** ៥៣១

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩១៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេដរ ជេ ស៊ី អាយ** ៥៣៣

១៨-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩១៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទ៉េង ស៊ុផល ណេតវើក ឌីហ្សាញ & ខនស្ត្រាក់សិន** ៥៣៥

២១-៧-២០០៨ -លិខិតបញ្ជាក់លេខ ៣៩៥៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សល & ខ្មែរជី** ៥៣៦.ក

៦៧

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានបំពាក់ឋានន្តរស័ក្តិកងយោធពលខេមរភូមិន្ទ និងតែងតាំងជាទីប្រឹក្សាក្រសួងការពារជាតិ ដែលមានសមាសភាពដូចខាងក្រោម:

១-ឯកឧត្តម **មួង សុភា** បំពាក់ឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី និងជា ទីប្រឹក្សាក្រសួងការពារជាតិ មានឋានៈស្មើអនុរដ្ឋលេខាធិការ

២-ឯកឧត្តម **មាស សុវណ្ណា** បំពាក់ឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី និងជា ទីប្រឹក្សាក្រសួងការពារជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្ត ឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

លេខ : ៤០ ច.ល

ជើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ប៊ុន ជិនកេន

៣៤.០១០១.០៤៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ :. ត្រូវបានតែងតាំងប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម:

១-ឯកឧត្តម **កឹម គុណាវឌ្ឍន៍** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកទូរទស្សន៍ជាតិកម្ពុជា(ទទក) មានឋានៈស្មើរដ្ឋលេខាធិការ

២-ឯកឧត្តម **គន់ យ៉ាន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកវិទ្យុជាតិកម្ពុជា(អ៊ែ.អិន.កា) មានឋានៈស្មើ រដ្ឋលេខាធិការ

៣-លោកជំទាវ **គិត គឹមហ៊ួន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយិការទីភ្នាក់ងារសារពត៌មានកម្ពុជា អាកាសេ មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្ត ឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩ល.០៩០១.០៤៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩

លេខ : ៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមករា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

នស/រកត/០១០៩/០៤៩

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត /០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំង ទីប្រឹក្សា និង ជំនួយការ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ :

១- ឯកឧត្តម ហ៊ុល ផានី ជា ទីប្រឹក្សា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។
២- លោកជំទាវ ឆួច ផានី ជា ទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។
៣- លោកជំទាវ ទី សាមីន ជា ទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។
៤- ឯកឧត្តម គួច កែមរី ជា ជំនួយការ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៩០១.០៤៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩

លេខ : ៥៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុន ចាន់ថុល

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៤៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥/ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឯកឧត្តម រ៉ុត ឧុទ្ធី ជាអគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានឋានៈស្មើ *អគ្គនាយក* ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ : ៥៥ ច.ល

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មករា ឆ្នាំ២០០៩

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ប៊ុន ប៊ុនកេន

៣រល.០៩០១.០៤៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩*

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ជូនចំពោះ :
១-លោកវរសេនីយ៍ទោ អ៊ុង វឌ្ឍា
២-លោកវរសេនីយ៍ទោ ប្រាក់ ហៀង
៣-លោកវរសេនីយ៍ទោ សួយ ចាន់សឿន
៤- លោកវរសេនីយ៍ត្រី ផុន សោភ័ណ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនចំពោះ :
១- លោក យឹម យោន
២- លោក ឡូន សុគន្ធា
៣-លោកវរសេនីយ៍ទោ សេ សុទ្ធី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ : ៥៤ ច.ល
បានឃើញ ប្រើមិនប្រែប្រួលចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០៩
ទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុំ ជិនកេន

៣រ៧.០៩០១.០៥០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៥២

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជរា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ជូនចំពោះ :

១-ឯកឧត្តមឧត្តមសេនីយឯក ស៊ឹម សុផល
២-ឯកឧត្តមឧត្តមសេនីយទោ ម៉ឹក ជាវ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤.០១០១.០៥២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩

លេខ : ៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
យុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តិទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ត្រូវបង្កើតលេខាធិការដ្ឋានមួយ ដើម្បីធ្វើជាសេនាធិការឱ្យគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលហៅកាត់ថា "លេខាធិការដ្ឋាន គ.ជ.អ.ប "។

**មាត្រា ២.–**

លេខាធិការដ្ឋាន គ.ជ.អ.ប មានទីតាំងស្ថិតនៅក្នុងទីស្តីការក្រសួងមហាផ្ទៃ។

## ជំពូកទី២
## តួនាទី ភារកិច្ច

**មាត្រា ៣.–**

លេខាធិការដ្ឋាន គ.ជ.អ.ប មានតួនាទីធ្វើជាសេនាធិការជូន គ.ជ.អ.ប ក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

**មាត្រា ៤.–**

លេខាធិការដ្ឋាន គ.ជ.អ.ប មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- សម្របសម្រួលកិច្ចការប្រចាំថ្ងៃរបស់ គ.ជ.អ.ប ស្របតាមការណែនាំ និងការសម្រេចរបស់ គ.ជ.អ.ប

- សហការសម្របសម្រួលជាមួយអនុគណៈកម្មាធិការនៃគ.ជ.អ.ប ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ ដើម្បីរៀបចំសេចក្តីព្រាងកម្មវិធីជាតិ ផែនការសកម្មភាព លិខិតបទដ្ឋានអនុវត្តច្បាប់ និងឯកសារនានាតាមការកំណត់របស់ គ.ជ.អ.ប ដើម្បីសុំការសម្រេចពី គ.ជ.អ.ប

- ត្រៀមរៀបចំកិច្ចប្រជុំទាំងអស់របស់ គ.ជ.អ.ប

- ជួយគាំទ្រ និងផ្តល់យោបល់ដល់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប

- ធ្វើការពិនិត្យសង្ខេបបូកសរុបឯកសារ របាយការណ៍លទ្ធផល នៃកិច្ចប្រជុំ អនុសាសន៍ សំណើ សំណូមពរ ដែលផ្តល់ជូនដោយអនុគណៈកម្មាធិការនានា ដោយភ្ជាប់ជាមួយអនុសាសន៍របស់ខ្លួន ដើម្បីដាក់ជូន គ.ជ.អ.ប

- ផ្សព្វផ្សាយព័ត៌មានជូនសាធារណជនអំពីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ

- សម្របសម្រួល និងរៀបចំឱ្យមានការពិគ្រោះយោបល់នានានៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងជាមួយអន្តរជាតិ អំពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ស្របតាមការណែនាំរបស់ គ.ជ.អ.ប

- ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

- សម្របសម្រួលគម្រោងគាំទ្រពីដៃគូអភិវឌ្ឍន៍នានាដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមការណែនាំពីគ.ជ.អ.ប

- អាចធ្វើជាប្រតិបត្តិករនូវគម្រោង កម្មវិធីដែលគាំទ្រពីដៃគូអភិវឌ្ឍន៍នានា តាមការសម្របសម្រួលគ្នារវាងដៃគូអភិវឌ្ឍន៍ទាំងនោះ និងតាមការសម្រេចរបស់ គ.ជ.អ.ប

- ចូលរួមជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- គ្រប់គ្រងថវិកា និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប

- បំពេញការងារផ្សេងៗទៀតតាមការកំណត់របស់ គ.ជ.អ.ប ។

**មាត្រា ៥.-**

លេខាធិការដ្ឋាន អាចទទួលបានការធ្វើប្រតិភូកម្មការងារតាមការចាំបាច់ពី គ.ជ.អ.ប ហើយគ.ជ.អ.ប ក៏អាចដកយកសិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្មនោះមកវិញបានដែរ។

## ជំពូកទី៣

## រចនាសម្ព័ន្ធ

**មាត្រា ៦.-**

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវដឹកនាំដោយប្រធាន ០១រូប អមដោយអនុប្រធាន ០៣រូប ជាជំនួយការ។

ប្រធានលេខាធិការដ្ឋាន ជារដ្ឋលេខាធិការ ០១រូប នៃក្រសួងមហាផ្ទៃ។

អនុប្រធានទី១ នៃលេខាធិការដ្ឋាន គឺជាអគ្គនាយករដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។

អនុប្រធាន ០២រូបទៀត នៃលេខាធិការដ្ឋាន មានឋានៈស្មើអគ្គនាយក។

ប្រធាន និងអនុប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធាន គ.ជ.អ.ប។

**មាត្រា ៧.-**

លេខាធិការដ្ឋានមានអង្គភាពចំណុះ ដូចខាងក្រោម :

- អង្គភាពគាំទ្រកម្មវិធី
- អង្គភាពគាំទ្រគោលនយោបាយ
- អង្គភាពអន្តរក្រសួង ។

អង្គភាពនីមួយៗត្រូវដឹកនាំដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនជាជំនួយការ។

ប្រធានអង្គភាពមានឋានៈស្មើអគ្គនាយករង អនុប្រធានអង្គភាពមានឋានៈស្មើប្រធាននាយកដ្ឋាន ដែលត្រូវតែងតាំងឡើងដោយអនុក្រឹត្យតាមសំណើរបស់ប្រធាន គ.ជ.អ.ប។

តួនាទី និងភារកិច្ចរបស់អង្គភាពនីមួយៗ នឹងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.អ.ប ។

**មាត្រា ៨.-**

អនុប្រធានលេខាធិការដ្ឋាន ប្រធាន អនុប្រធាន និងបុគ្គលិកតាមអង្គភាពនានានៃលេខាធិការដ្ឋាន ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ និងមន្ត្រីនៃក្រសួង ស្ថាប័នក្នុង គ.ជ.អ.ប ដែលមានចំណេះដឹង និងបទពិសោធន៍ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

មន្ត្រីពីក្រសួង ស្ថាប័ននានាក្រៅពីក្រសួងមហាផ្ទៃ ដែលបានជ្រើសរើសឱ្យមកបំពេញការងារក្នុងលេខាធិការដ្ឋានក្រៅពីមុខតំណែងអនុប្រធានលេខាធិការដ្ឋាន និងប្រធាន អនុប្រធានអង្គភាពនៃលេខាធិការដ្ឋាន ត្រូវខិតខំលៃលកបំពេញការងារ យ៉ាងហោចណាស់ឱ្យបានពាក់កណ្ដាលម៉ោងធ្វើការសម្រាប់ការងារលេខាធិការដ្ឋាន និងពាក់កណ្ដាលម៉ោងទៀតត្រូវបំពេញការងារនៅក្រសួង ស្ថាប័នសាមី ។

គ.ជ.អ.ប ត្រូវចេញសេចក្ដីសម្រេច ដើម្បីកំណត់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសមន្ត្រីពីក្រសួង ស្ថាប័ននានាមកបំពេញការងារក្នុងលេខាធិការដ្ឋាន ព្រមទាំងលក្ខខណ្ឌការងារសម្រាប់ការបំពេញការងារខាងលើនេះ ។

**មាត្រា ៩.-**

លេខាធិការដ្ឋានអាចធ្វើការជ្រើសរើសទីប្រឹក្សា ឬជំនាញការជាតិ ឬអន្តរជាតិ និងបុគ្គលិកជាប់កិច្ចសន្យា ដើម្បីជួយការងារលេខាធិការដ្ឋានតាមការចាំបាច់ ។

ទីប្រឹក្សា ឬជំនាញការជាតិ ឬអន្តរជាតិ និងបុគ្គលិកជាប់កិច្ចសន្យា មិនមែនជាបុគ្គលិករបស់លេខាធិការដ្ឋានឡើយ ។

គ.ជ.អ.ប ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ខ្លួន នូវតម្រូវការទីប្រឹក្សា ឬជំនាញការ និងបុគ្គលិកជាប់កិច្ចសន្យា លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស លក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សា ឬជំនាញការ និងបុគ្គលិកជាប់កិច្ចសន្យាខាងលើនេះ ដោយឈរលើមូលដ្ឋាននៃប្រសិទ្ធភាពការងារ ។

## ជំពូកទី៤
## អំពីរបៀបរបបការងារ

**មាត្រា ១០.-**

ប្រធានលេខាធិការដ្ឋាន ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះ គ.ជ.អ.ប ចំពោះកិច្ចដំណើរការគ្រប់ផ្នែកទាំងអស់នៃលេខាធិការដ្ឋាន ។

**មាត្រា ១១.-**

ក្នុងការអនុវត្តការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្ដីសម្រេចរបស់ គ.ជ.អ.ប ក្នុងករណីមានភារកិច្ចដែលពាក់ព័ន្ធនឹងគោលនយោបាយ ឬការងារបន្ទាន់ចាំបាច់ណាមួយ ប្រធានលេខាធិការដ្ឋានត្រូវសុំយោបល់ដឹកនាំ ណែនាំដោយផ្ទាល់ពីប្រធាន គ.ជ.អ.ប ។

**មាត្រា ១២.-**

លេខាធិការដ្ឋាន ត្រូវសហការសម្របសម្រួលជាមួយអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ ដើម្បីគាំទ្រដល់កិច្ចដំណើរការប្រចាំថ្ងៃរបស់លេខាធិការដ្ឋាន ។

គ.ជ.អ.ប អាចកំណត់ដោយសេចក្ដីសម្រេចបន្ថែមទៀតនូវកិច្ចសហការសម្របសម្រួល និងទំនាក់ទំនងខាងលើនេះ ។

**មាត្រា ១៣.-**

ប្រធានលេខាធិការដ្ឋាន គឺជាប្រធានបុគ្គលិកទាំងអស់របស់លេខាធិការដ្ឋាន រួមទាំងអនុប្រធានលេខាធិការដ្ឋាន ប្រធាន អនុប្រធានអង្គភាពនៃលេខាធិការដ្ឋានផង ។

**មាត្រា ១៤.-**

អនុប្រធានលេខាធិការដ្ឋានត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានលេខាធិការដ្ឋាន ហើយត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះប្រធានលេខាធិការដ្ឋាន និងអាចជំនួសប្រធានលេខាធិការដ្ឋានតាមឋានានុក្រម ក្នុងពេលប្រធានលេខាធិការដ្ឋានអវត្តមាន ។

**មាត្រា ១៥.-**

ប្រធានអង្គភាពទាំងអស់ ត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះប្រធានលេខាធិការដ្ឋាន ។

**មាត្រា ១៦.-**

បុគ្គលិកតាមអង្គភាពនានានៃលេខាធិការដ្ឋាន ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានអង្គភាពរបស់ខ្លួន និងមានការទទួលខុសត្រូវ និងគណនេយ្យភាពដោយប្រយោលចំពោះប្រធានលេខាធិការដ្ឋាន ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១៧.-**

ក្នុងពេលមិនទាន់រៀបចំបានលេខាធិការដ្ឋាន គ.ជ.អ.ប តាមគោលការណ៍នៃអនុក្រឹត្យនេះ លេខាធិការដ្ឋាននៃ គ.ជ.វ.វ ត្រូវធ្វើជាលេខាធិការដ្ឋានបណ្តោះអាសន្ននៃ គ.ជ.អ.ប ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩.-**

ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ១៩*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តិទៅ នៃអនុគណៈកម្មាធិការចំណុះគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីសមាសភាព តួនាទី ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តិទៅនៃអនុគណៈកម្មាធិការ ចំណុះគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ( គ.ជ.អ.ប )។

## ជំពូកទី២

## អនុគណៈកម្មាធិការនៃ គ.ជ.អ.ប

**មាត្រា ២.-**

គ.ជ.អ.ប ត្រូវមានអនុគណៈកម្មាធិការជាជំនួយការ ដូចខាងក្រោម ÷

- អនុគណៈកម្មាធិការមុខងារ និងធនធាន
- អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ
- អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ

ក្រៅពីអនុគណៈកម្មាធិការខាងលើនេះ គ.ជ.អ.ប អាចស្នើសុំបង្កើតអនុគណៈកម្មាធិការបន្ថែមទៀត តាមការចាំបាច់។

**មាត្រា ៣.-**

អនុគណៈកម្មាធិការនីមួយៗនៃ គ.ជ.អ.ប មានសមាសភាពដូចខាងក្រោម ÷

**ក-អនុគណៈកម្មាធិការមុខងារ និងធនធាន**

| | |
|---|---|
| - រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | ប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី | អនុប្រធាន |
| - រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នរបស់ គ.ជ.អ.ប | សមាជិក |
| - តំណាងមួយរូបពីក្រុមប្រឹក្សាតាមប្រភេទនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក ។ |

**ខ-អនុគណៈកម្មាធិការសារពើពន្ធ និងហិរញ្ញវត្ថុ**

| | |
|---|---|
| - រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងផែនការ | អនុប្រធាន |
| - រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នរបស់ គ.ជ.អ.ប | សមាជិក |
| - តំណាងមួយរូបពីក្រុមប្រឹក្សាតាមប្រភេទនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក ។ |

**គ-អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធាន
- រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ អនុប្រធាន
- រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន
- រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នរបស់ គ.ជ.អ.ប សមាជិក
- តំណាងមួយរូបពីក្រុមប្រឹក្សាតាមប្រភេទនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក ។

**ឃ-អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ**

- រដ្ឋលេខាធិការ នៃក្រសួងផែនការ ប្រធាន
- រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ អនុប្រធាន
- រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន
- រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នរបស់ គ.ជ.អ.ប សមាជិក
- តំណាងមួយរូបពីក្រុមប្រឹក្សាតាមប្រភេទនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក ។

**មាត្រា ៤.-**

រដ្ឋលេខាធិការដែលទទួលជាប្រធានអនុគណៈកម្មាធិការ អនុប្រធានអនុគណៈកម្មាធិការ និងរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការដែលទទួលជាសមាជិកអនុគណៈកម្មាធិការ ត្រូវចាត់តាំងដោយរដ្ឋមន្ត្រី ឬប្រធានស្ថាប័ននៃក្រសួង ស្ថាប័ននោះ ហើយដែលទទួលស្គាល់ដោយ គ.ជ.អ.ប ។

**មាត្រា ៥.-**

សមាគមក្រុមប្រឹក្សាតាមប្រភេទនីមួយៗដែលបានបង្កើត និងចុះបញ្ជីស្របតាមនីតិវិធីកំណត់ ត្រូវជ្រើសរើសតំណាងម្នាក់ៗ ដើម្បីធ្វើជាសមាជិកអនុគណៈកម្មាធិការនីមួយៗ ។

ករណីក្រុមប្រឹក្សាប្រភេទណាមួយ មិនទាន់បានបង្កើតសមាគមតាមនីតិវិធីដែលកំណត់ សមាជិកភាពនៃតំណាងនោះក្នុងអនុគណៈកម្មាធិការត្រូវរក្សាទុកឱ្យនៅទំនេររហូតដល់ក្រុមប្រឹក្សាប្រភេទនោះបង្កើតបានសមាគម ។

**មាត្រា ៦.-**

អនុគណៈកម្មាធិការនីមួយៗ អាចអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍អន្តរជាតិ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ឱ្យចូលសង្កេតការណ៍ក្នុងកិច្ចប្រជុំរបស់ខ្លួន ឬអាចធ្វើការពិគ្រោះពិភាក្សា ដើម្បីប្រមូលអនុសាសន៍ពីតំណាង ឬ អ្នកពាក់ព័ន្ធទាំងនោះតាមការចាំបាច់ ។

**មាត្រា ៧.-**

អនុគណៈកម្មាធិការនីមួយៗត្រូវបង្កើតក្រុមការងារ ដើម្បីជួយសិក្សាអំពីបញ្ហានានា ដែលពាក់ព័ន្ធនឹងភារកិច្ចរបស់ខ្លួន ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងាររបស់អនុគណៈកម្មាធិការត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.អ.ប ។

**មាត្រា ៨.-**

ក្រសួង ស្ថាប័ននីមួយៗនៃ គ.ជ.អ.ប ត្រូវបង្កើតឱ្យមានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ ប្រចាំក្រសួង ស្ថាប័នរបស់ខ្លួន។

ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការប្រចាំក្រសួង ស្ថាប័ននីមួយៗ ត្រូវស្ថិតក្រោមការដឹកនាំដោយផ្ទាល់របស់រដ្ឋមន្ត្រី ឬប្រធាន ស្ថាប័ននៃក្រសួង ស្ថាប័ននោះ។

ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការប្រចាំក្រសួង ស្ថាប័ននីមួយៗ មានភារកិច្ចរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលពាក់ព័ន្ធមុខងារ និងការទទួលខុសត្រូវនៃក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីអនុវត្ត ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ផែនការសកម្មភាព ព្រមទាំងសេចក្តីសម្រេចរបស់គ.ជ.អ.ប ហើយត្រូវចូលរួមគាំទ្រដល់សកម្មភាពអនុគណៈកម្មាធិការ និងសកម្មភាពរបស់ គ.ជ.អ.ប ។

គ.ជ.អ.ប អាចធ្វើការណែនាំអំពីទំនាក់ទំនងការងារ កិច្ចសហការ និងការគាំទ្រពីក្រុមការងារវិមជ្ឈការ និង វិសហមជ្ឈការ ប្រចាំក្រសួង ស្ថាប័នជាមួយយន្តការនានារបស់ខ្លួន។

## ជំពូកទី៣

## ភារកិច្ចជាក់ស្តែងរបស់អនុគណៈកម្មាធិការ

**មាត្រា ៩.-**

អនុគណៈកម្មាធិការមុខងារ និងធនធានមានភារកិច្ចជួយ និងផ្តល់យោបល់ ព្រមទាំងអនុសាសន៍ដល់ គ.ជ.អ.ប លើការងារទាំងអស់ដែលទាក់ទងដល់ភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប ក្នុងការកំណត់ និងការផ្ទេរមុខងារ និងធនធានឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១០.-**

អនុគណៈកម្មាធិការសារពើពន្ធ និងហិរញ្ញវត្ថុ មានភារកិច្ចជួយ និងផ្តល់យោបល់ ព្រមទាំងអនុសាសន៍នានាដល់ គ.ជ.អ.ប លើការងារទាំងអស់ ដែលទាក់ទងដល់ភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប អំពីកិច្ចការសារពើពន្ធ ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១១.-**

អនុគណៈកម្មាធិការបុគ្គលិករបស់ថ្នាក់ក្រោមជាតិ មានភារកិច្ចជួយ និងផ្តល់យោបល់ដល់ គ.ជ.អ.ប លើការងារទាំងអស់ដែលទាក់ទងនឹងភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប ក្នុងការកំណត់ ការរៀបចំបុគ្គលិក ការរៀបចំឱ្យមានក្របខ័ណ្ឌបុគ្គលិកសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១២.-**

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ មានភារកិច្ចជួយ និងផ្ដល់យោបល់ដល់ គ.ជ.អ.ប លើការងារទាំងអស់ដែលទាក់ទងនឹងភារកិច្ច និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប អំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១៣.-**

គ.ជ.អ.ប អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់អនុគណៈកម្មាធិការរបស់ខ្លួនតាមការចាំបាច់។

## ជំពូកទី៤

## តួនាទី និងរបៀបរបបការងាររបស់អនុគណៈកម្មាធិការ

**មាត្រា ១៤.-**

អនុគណៈកម្មាធិការ នៃគ.ជ.អ.ប មានតួនាទីធ្វើការសិក្សា លើកយោបល់ និងផ្ដល់អនុសាសន៍រាល់កិច្ចការដែលស្ថិតក្នុងវិសាលភាពនៃភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន ដើម្បីដាក់ជូន គ.ជ.អ.ប ពិនិត្យ សម្រេច។

**មាត្រា ១៥.-**

ក្នុងការសិក្សា ពិគ្រោះពិភាក្សា ដើម្បីលើកយោបល់ និងផ្ដល់អនុសាសន៍ជូន គ.ជ.អ.ប អនុគណៈកម្មាធិការនីមួយៗត្រូវពុះពារ ដើម្បីបង្កើត ជំរុញ និងទ្រទ្រង់ដល់និរន្តរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា ១៦.-**

អនុគណៈកម្មាធិការនៃ គ.ជ.អ.ប ត្រូវអនុវត្តភារកិច្ច និងការទទួលខុសត្រូវដែលបានកំណត់ ដោយផ្អែកតាម អត្ថន័យ គោលបំណង និងឆន្ទៈនៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

**មាត្រា ១៧.-**

ដើម្បីផ្ដល់យោបល់ និងអនុសាសន៍នានាដល់ គ.ជ.អ.ប អនុគណៈកម្មាធិការត្រូវធ្វើការពិគ្រោះយោបល់ជាមុនជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។

**មាត្រា ១៨.-**

ក្នុងការអនុវត្តការងាររបស់ខ្លួន អនុគណៈកម្មាធិការនីមួយៗត្រូវផ្អែកតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផែនការសកម្មភាព និងសេចក្ដីសម្រេចនានារបស់ គ.ជ.អ.ប។

**មាត្រា ១៩.-**

អនុគណៈកម្មាធិការត្រូវតាមដាន ត្រួតពិនិត្យ និងធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំជូន គ.ជ.អ.ប ឬរបាយការណ៍តាមពេលវេលាជាក់លាក់ណាមួយដែលកំណត់ដោយ គ.ជ.អ.ប ទាក់ទិននឹងកិច្ចការដែលស្ថិតក្នុងវិសាលភាពនៃភារកិច្ច និងសិទ្ធិអំណាចរបស់អនុគណៈកម្មាធិការនីមួយៗ ។

សេចក្តីរាយការណ៍ និងអនុសាសន៍ខាងលើត្រូវបញ្ជូនមកលេខាធិការដ្ឋាន ដើម្បីសម្របសម្រួល និងបំពេញបែបបទដាក់ជូន គ.ជ.អ.ប ពិនិត្យ សម្រេចឱ្យបានសមស្រប និងទាន់ពេលវេលា។

**មាត្រា ២០.-**

គ.ជ.អ.ប អាចធ្វើប្រតិភូកម្មនូវកិច្ចការដែលស្ថិតក្នុងវិសាលភាពនៃភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនជូនអនុគណៈកម្មាធិការ បន្ថែមពីលើភារកិច្ច និងសិទ្ធិអំណាចជាក់លាក់របស់អនុគណៈកម្មាធិការ។

ក្នុងការធ្វើប្រតិភូកម្មខាងលើនេះ គ.ជ.អ.ប អាចប្រគល់ភារកិច្ចឱ្យអនុគណៈកម្មាធិការច្រើនជាងមួយ ដើម្បី សហការគ្នាសិក្សាលើកយោបល់ និងផ្តល់អនុសាសន៍តាមការចាំបាច់ ។

**មាត្រា ២១.-**

លេខាធិការដ្ឋាននៃ គ.ជ.អ.ប គឺជាលេខាធិការដ្ឋាននៃអនុគណៈកម្មាធិការ ។

**មាត្រា ២២.-**

អនុគណៈកម្មាធិការនីមួយៗត្រូវបំពេញការងារតាមការចាត់ចែងរបស់ប្រធានអនុគណៈកម្មាធិការ ហើយត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានអនុគណៈកម្មាធិការ ។

អនុប្រធានអនុគណៈកម្មាធិការត្រូវជំនួសប្រធានក្នុងពេលប្រធានអនុគណៈកម្មាធិការអវត្តមាន។

**មាត្រា ២៣.-**

កិច្ចប្រជុំអនុគណៈកម្មាធិការអាចយកជាការបាន លុះត្រាតែមានវត្តមានសមាជិកអនុគណៈកម្មាធិការលើសពីពាក់កណ្តាលនៃសមាជិកអនុគណៈកម្មាធិការទាំងមូលបានចូលរួម ។

**មាត្រា ២៤.-**

ក្នុងការលើកយោបល់ ឬផ្តល់អនុសាសន៍នានាជូន គ.ជ.អ.ប អនុគណៈកម្មាធិការត្រូវខិតខំសម្របសម្រួលឱ្យមានការមូលមតិគ្នានៅក្នុងចំណោមសមាជិកអនុគណៈកម្មាធិការដែលមានវត្តមានក្នុងកិច្ចប្រជុំ។ ក្នុងករណីមិនមានការមូលមតិគ្នាបាន អនុគណៈកម្មាធិការត្រូវធ្វើការសម្រេចដោយសម្លេងភាគច្រើននៃសមាជិកអនុគណៈកម្មាធិការទាំងមូល ។

**មាត្រា ២៥.-**

លេខាធិការដ្ឋានត្រូវចាត់មន្ត្រីក្នុងលេខាធិការដ្ឋានឱ្យចូលរួមក្នុងគ្រប់កិច្ចប្រជុំរបស់អនុគណៈកម្មាធិការ ។

អនុគណៈកម្មាធិការ អាចអនុញ្ញាតឱ្យមន្ត្រី ឬអ្នកពាក់ព័ន្ធនានាចូលរួមប្រជុំអនុគណៈកម្មាធិការតាមការចាំបាច់។ មន្ត្រីដែលចូលរួមប្រជុំខាងលើនេះ មានសិទ្ធិផ្តល់យោបល់ដល់អនុគណៈកម្មាធិការ ប៉ុន្តែគ្មានសិទ្ធិអនុម័តលើការសម្រេចណាមួយរបស់អនុគណៈកម្មាធិការបានឡើយ ។

**មាត្រា ២៦.-**

រាល់កិច្ចប្រជុំទាំងអស់របស់អនុគណៈកម្មាធិការ ត្រូវមានកំណត់ហេតុប្រជុំដែលរៀបចំដោយក្រុមការងារ នៃអនុគណៈកម្មាធិការ ។

កំណត់ហេតុប្រជុំនៃអង្គប្រជុំនីមួយៗ ត្រូវផ្ដល់ជូនលេខាធិការដ្ឋានយ៉ាងយូរប្រាំ (០៥) ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ ។ លេខាធិការដ្ឋានត្រូវធ្វើការបូកសរុបលទ្ធផលនៃកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនានា ដើម្បីរាយការណ៍សុំការសម្រេចពី គ.ជ.អ.ប ។

**មាត្រា ២៧.-**

គ.ជ.អ.ប អាចកំណត់បន្ថែមទៀតអំពីរបៀបរបបការងាររបស់អនុគណៈកម្មាធិការនានាតាមការចាំបាច់ ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ២៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៩.-**

ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល និងសមាសភាពដូចមានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>**កន្លែងទទួល**</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ២៩*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក. ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួល នាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក , ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតំឡើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១**: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៦.១២៦ លានរៀល ( ប្រាំមួយពាន់មួយរយម្ភៃប្រាំមួយលានរៀលគត់ ) ពីជំពូក ០៩ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ ( ការទិញ ) ចំនួន ១.៤៣៧ លានរៀល មកជំពូក ៦១ ( សេវាខាងក្រៅ ) ចំនួន ៣១៥ លានរៀល មកជំពូក ៦២ ( សេវាខាងក្រៅផ្សេងៗ ) ចំនួន ៤.០២៦ លានរៀល និង មកជំពូក ៦៤ ( បន្ទុកបុគ្គលិក ) ចំនួន ៣៤៨ លានរៀល ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

**មាត្រា២**: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់រៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាខណ្ឌ ឆ្នាំ ២០០៩ ។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជំរាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត់ ចាន់ថុល**

**រដ្ឋមន្ត្រីស្តីទី**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧៣ អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពីការតែងតាំងនាយឧត្តមសេនីយ៍ (ជាន់ខ្ពស់)

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រម លេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គមេបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមការចាំបាច់

**សម្រេច**

**មាត្រា ១:** តែងតាំងឧត្តមនាវីឯក **ទៀ វិញ** អត្តលេខ ០០០១៧១ ជាមេបញ្ជាការកងទ័ពជើងទឹក នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៤.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/០៧០២/០១៥ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០០៦ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធជំងឺអេដស៍
- យោងតាមសំណើរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

### សម្រេច

**មាត្រា១:** ត្រូវបានតែងតាំងជំនួយការឯកឧត្តម ទុត សុខុម ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម:

១-លោក **ស៊ឹម មុណ្ណា** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**

២-លោក **នុត សុភាព** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

PSSD-1/15/2009

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៧៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

### ស ម្រេ ច

**មាត្រា ១:** តែងតាំងមន្ត្រីរាជការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន០៣រូប មានដូចខាងក្រោម :

១- លោក **ហ៊ី វីរៈ** បច្ចុប្បន្នអធិការ ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន

២- លោក **ឈឹម ផល្លា** បច្ចុប្បន្នប្រធានការិយាល័យ ជាអធិការ នៃអគ្គាធិការដ្ឋាន

៣- លោក **អ៊ុយ សុផល** បច្ចុប្បន្នអនុប្រធានអង្គភាព ជាអធិការ នៃអគ្គាធិការដ្ឋាន

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណ-ការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៩
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា "៣"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
